ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៤...សសរ

# សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការសម្របសម្រួលការងារប្រក្រតីនីយកម្ម នៃទំនាក់ទំនងកម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :**

- បង្កើតគណៈកម្មការសម្របសម្រួលការងារប្រក្រតីនីយកម្ម នៃទំនាក់ទំនងកម្ពុជា-ថៃ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | សុខ | អាន | ប្រធាន |
| ២- | ឯកឧត្តម | ប្រាក់ | សុខុន | អនុប្រធាន |
| ៣- | ឯកឧត្តម | ព្រុំ | សុខា | សមាជិក |
| ៤- | ឯកឧត្តម | អ៊ុក | រ៉ាប៊ុន | សមាជិក |
| ៥- | ឯកឧត្តម | ឡុង | វិសាលោ | សមាជិក |
| ៦- | ឯកឧត្តម | យូ | ស៊ិនឡុង | សមាជិក |
| ៧- | ឯកឧត្តម | មល់ | រឿប | សមាជិក |
| ៨- | ឯកឧត្តម | ក្រាញ់ | តូនី | សមាជិក |
| ៩- | លោក | ជា | វ៉ាន់ដេត | សមាជិក |

**ប្រការ ២ :**

- គណៈកម្មការនេះមានភារកិច្ចធ្វើប្រក្រតីនីយកម្មទំនាក់ទំនងកម្ពុជា- ថៃ ក្រោយឧបទ្ទវហេតុ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៣ ។

**ប្រការ ៣ :**

- គណៈកម្មការសម្របសម្រួលការងារប្រក្រតីនីយកម្ម នៃទំនាក់ទំនងការងារកម្ពុជា- ថៃ មានតួនាទីជាចំណុចកណ្ដាលក្នុងការសម្របសម្រួលកិច្ចការទាំងឡាយ ដែលពាក់ព័ន្ធនឹងការធ្វើប្រក្រតីនីយកម្ម នៃទំនាក់ទំនងកម្ពុជា- ថៃ ។

**ប្រការ ៤ :**

- គណៈកម្មការសម្របសម្រួលការងារប្រក្រតីនីយកម្ម នៃទំនាក់ទំនងការងារកម្ពុជា- ថៃ ត្រូវប្រមូលសរុបការងារទាំងឡាយដូចមានចែងក្នុងប្រការ ៣ នៃសេចក្ដីសម្រេចនេះ រាយការណ៍ជូនសម្ដេចនាយករដ្ឋមន្ត្រី ។

**ប្រការ ៥ :**

- គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្ដីការគណៈរដ្ឋមន្ត្រីលើលិខិតផ្លូវការ ។

**ប្រការ ៦ :**

- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង- ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្ដីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៣*

**ហ៊ុន សែន**

<u>***កន្លែងទទួល :***</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *ឯកសារ- កាលប្បវត្តិ*